# ជោគឫក្សទេវសិទ្ធិ

ធ្វើការសារពើ បើចង់បានសុខសួស្តី ចូរសង្កេតនិងពិចារណារើសយកចំណុចសំខាន់នូវជោគឫក្ស "ទេវសិទ្ធិ"បានល្អ ពេលណាពេលនោះជាជោគមង្គលហោង ។

ក្នុងទីនេះ "ជោគឫក្សទេវសិទ្ធិ"ជាការចាំបាច់រើសពេលរៀបសំពះទទួលស្វាគមជ័យ នៅពេលដែលនក្ខត្តឫក្សចរចូលកាន់ជោគទាំង៥ ជោគណាមួយ ។

លោកអ្នកដឹកនាំកិច្ចមង្គលការ សូមជ្រាបថា ពាក្យដែលនិយមហៅ"ពេលា"មានចំណុច៣ ស្ថានគឺ :

១-ជោគអាយុប្រុស-ស្រីបានកេណ្ឌ ត្រូវជោគល្អ

២-ជោគចេកមាស ឫជោគខែប្រចាំថ្ងៃ និងជោគរួមខ្មើយ

៣-ជោគឫក្សទេវសិទ្ធិ ជាជោគរើសពេលសំពះ ។

តាមហេតុពិត ពេលដែលសមគួរ និងពេលដែលមិនគួរនាំសាមីខ្លួនប្រុសឡើងក្រាបសំពះផ្ទួបហត្ថាជាសញ្ញា ឬជានិមិត្តនៃការងាររួម( ស្នេហា) គប្បីរើសរកពេលដែលប្រកបទៅដោយជោគឫក្សយ៉ាងនេះ ។

## ខាងខ្នើត

ថ្ងៃ ១ កើត ទេពចរទាំងនៅចំបេះដូង នារាយណ៍ឱ្យឫក្ស ផ្តើមធ្វើការសារពើបានល្អ ហាមកុំចេញចរទៅកាន់ទីឆ្ងាយតាមជើងគោក លាភផលបានដោយសារស្រីមេម៉ាយ ជោគល្អតាំងពីព្រឹកម៉ោង ៦ ដល់ល្ងាចម៉ោង ៦ ជោគអាក្រក់តាំងពីល្ងាចម៉ោង ៦ និង ១នាទី ទៅដល់មាន់រងាវភ្លឺម៉ោង ៥ អស់កំសួល ។

២ កើត ជីពចរនៅជើង កុំគប្បីសងគ្រឹះស្ថានថ្មីចងសម្ព័ន្ធស្ពីដណ្តឹងប្រពន្ធ រៀបមង្គលការរកកម្លោះក្រមុំ បើចង សម្ព័ន្ធ ឬរៀបអាពាហ៍ពិពាហ៍ មុខជានិរាសចោលគ្នា ឬក៏មានហេតុរឿងនឹងគ្នា ពុំនោះមានបង់ខាតទ្រព្យរបស់ ដូចជាសត្វ ជើង២ ឬជើង៤ ហើយមិនគួរចូលខ្លួនទៅនៃបនិត្យស្និទ្ធនឹងនាហ្មឺនឃុនម្ចាង និងចរចេញទៅជួញផ្សេងៗ ជាពិសេសកុំកាត់ដេរសំពត់ ជោគអាក្រក់តាំងពីម៉ោង ៦ព្រឹក ដល់ម៉ោង ៦ល្ងាច ជោគល្អចាប់តាំងពីម៉ោង ៦ និងនាទីល្ងាច ដល់ម៉ោង ៦ភ្លឺ ។

៣ កើត ជីពចរនៅចង្ការ ហាមកុំចូលព្រៃធំ ឬកាប់រំលំឈើធំ កុំចងសម្ព័ន្ធស្ពីដណ្តឹងប្រពន្ធ កុំរៀបអាពាហ៍ពិពាហ៍ ក្នុងថ្ងៃនេះចេះជួញបានចំណេញផលល្អ ចូលទៅធ្វើការជិតស្និទ្ធនឹងនាហ្មឺនមន្ត្រីបានប្រសើរ ។ ជោគអាក្រក់តាំងពីម៉ោង ៦ព្រឹក ដល់ម៉ោង ៦ល្ងាច ជោគល្អតាំងពីម៉ោង ៦ និង១នាទី ល្ងាច ដល់ម៉ោង ៦ភ្លឺ ។

៤ កើត ទេពចរនៅទីផ្លា ចាត់ចែងចងសម្ព័ន្ធគូគ្រង ឬរៀបអាពាហ៍ពិពាហ៍ប្រុស-ស្រីបានល្អ បាននៅរួមរស់ជាមួយគ្នាបានសេចក្តីស្ងួនគ្រងគ្នាស្និទ្ធល្អ ហាមកុំចេញចរធ្វើជំនួញលក់ដូរទ្រព្យមានជីវិត មុខជាលាញទ្រព្យអស់ ជោគល្អតាំងពី ម៉ោង ៦ ព្រឹក ដល់ម៉ោង៦ល្ងាច ជោគពេលាអាក្រក់តាំងពីម៉ោង ៥ល្ងាច ដល់ម៉ោង៦ព្រឹក ។

៥ កើត ជីពចរនៅជើង ហាមឫក្សកុំស្ដីដណ្តឹង ឬរៀបមង្គលការ បើរៀបការត្រូវមានការនិរាសព្រាត់ប្រាស់យ៉ាង ទាន់ហន់ពុំនោះសោតនឹងកើតមានមហន្តរាយតាមផ្ទន្ទាជាប់រឿយៗ ។ ជោគល្អតាំងពីម៉ោង ៦ ព្រឹក ដល់ម៉ោង ៦ល្ងាច ជោគអាក្រក់តាំងពីម៉ោង ៦ល្ងាច ដល់ម៉ោង ៦ព្រឹក ។

AZCambodia.com ABCCambodia.com AngkorDaily.com AngkorPost.com AngkorLink.com

៦ កើត ជីពចរនៅថ្ងាស ព្រះអាទិត្យឱ្យឫក្ស ចងសម្ព័ន្ធស្ពឹដណ្ដឹងគូស្រករ រៀបមង្គលការបានល្អ គ្រប់គ្រងរក្សាគ្នាបានយឺនយូរ មានវឌ្ឍនភាពបរិបូរណ៍ ។ ជោគល្អមានតាំងពីម៉ោង៦ព្រឹក ដល់ម៉ោង ៦ល្ងាច ជោគជាកាឡកិណីមានតាំងពីម៉ោង៦ល្ងាច ដល់ម៉ោង ៦ព្រឹក ។

៧ កើត ជីពចរនៅត្រចៀក ព្រះអាទិត្យហាមឫក្ស កុំគប្បីទទួលស្ដួលបាវព្រាវ កុំចងសម្ព័ន្ធស្ដីដណ្ដឹងគូស្រករ កុំរៀបចំអាពាហ៍ពិពាហ៍ បើបានគ្នាទៅមុខជាកើតមានសេចក្ដីទុក្ខវេទនា ព្រាត់ប្រាស់គ្នា ឬមានការខុសទាស់ចិត្តគំនិតគ្នាជា និច្ចនិរន្តរ៍ ។ ជោគអាក្រក់មានតាំងពីម៉ោង ៦ព្រឹក ដល់ម៉ោង៦ល្ងាច ជោគល្អតាំងពីម៉ោង ៦ល្ងាចដល់ម៉ោង ៦ព្រឹក ។

៨ កើត ជីពចរនៅទាំង៤ មុខ ក្រោយ និង សងខាង ព្រះអាទិត្យហាមឫក្ស កុំគប្បីធ្វើការចងសម្ព័ន្ធស្ដីដណ្ដឹងគូស្រកររៀបអាពាហ៍ពិពាហ៍ បានគ្នានឹងមានហេតុភេទជាទុក្ខព្រួយខកខាន ឬព្រាត់ប្រាស់និរាសចាកចោល ជោគកាឡកិណីមានតាំងពីម៉ោង១៣ និង១២នាទី ដល់ម៉ោង ៦ព្រឹក ជោគល្អតាំងពីម៉ោង ៦ និង១នាទីព្រឹក ដល់ម៉ោង ៦ល្ងាច ។

៩ កើត ជីពចរនៅភ្នែកទាំងសងខាង ព្រហស្បតិ៍ឱ្យឫក្ស ធ្វើការចងសម្ព័ន្ធស្ដីដណ្ដឹងគូស្រករ រៀបពិធីមង្គលការ បានល្អបានគ្នាមានសម្បត្តិសំបូរសុខ ប្រកបកិច្ចការបានលូតលាស់ចំរើន មូលមិត្តដោយបរិពារ ។

១០ កើត ព្រះសៅរ៍ឃាត់ហាមឫក្ស ទេពចរនៅក្បាល កុំគប្បីធ្វើការចងសម្ព័ន្ធមេត្រីស្ដីដណ្ដឹងគូស្រករ កុំរៀបមង្គលការកម្លោះ-ក្រមុំ បានគ្នាមុខតែមានការពុំស្រួលរឿយៗ ត្រូវរងទុក្ខទោសគ្មានចេះល្ហែ កាលក្ររហេមរហាមជា ពិសេស ។

១១ កើត ព្រះពុធឱ្យឫក្ស ទេពចរនៅពោះ គប្បីធ្វើការចងសម្ព័ន្ធមេត្រីស្ដីដណ្ដឹងគូគ្រង រៀបចំវិវាហមង្គលការយុវជននិងយុវនតី បានសេចក្ដីសុខក្សេមក្សាន្ត មានយសសក្ដិបរិពារចោមរោមជានិច្ចកាល បរិបូរណ៍ភោគសម្បត្តិនិងបានជាសន្តតិពង្ស ។

១២ កើត ព្រះពុធហាមឃាត់ឫក្ស មិនគប្បីផ្ដើមធ្វើការចងសម្ព័ន្ធមេត្រីស្ដីដណ្ដឹងគូគ្រង រៀបអាពាហ៍ពិពាហ៍ធ្វើជាស្វាមីភរិយា និងមានហេតុភេទរឿយៗ ពុំនោះមានសេចក្ដីក្ដៅក្រហាយបណ្ដាលឱ្យបែកបាក់ឃ្លាតចាកគ្នា នៅរួមគ្នាមិនបាន យឺនយូរបានសេចក្ដីសុចចិត្ត បានសេចក្ដីទុក្ខច្រើន ។

១៣ កើត ព្រះចន្ទ្រឱ្យឫក្ស ព្រះវិស្ណុកម្មប្រសិទ្ធិឫក្ស គប្បីធ្វើការចងសម្ព័ន្ធមេត្រីស្ដីដណ្ដឹងគូគ្រង រៀបពិធីមង្គលការគូស្វាមីភរិយាបានសុខសំបូរ មានវឌ្ឍនភាពជានិច្ចកាល ។ ជោគល្អតាំងពីម៉ោង ៦ព្រឹក ដល់ម៉ោង១៨ល្ងាច ជោគអាក្រក់មានតាំងពីម៉ោង១៨និង១នាទី ដល់ម៉ោង៦ព្រឹក ។

១៤ កើត ព្រះសៅរ៍ឃាត់ហាមឫក្ស ទេពចរនៅស្មាទាំងសងខាង មិនគប្បីធ្វើការចងសម្ព័ន្ធមេត្រីស្ដីដណ្ដឹងគូស្រករ រៀបអាពាហ៍ពិពាហ៍ បាននៅរួមរស់ជាមួយគ្នាអារឹះសេចក្ដីសុខណាស់ ច្រើនជួបប្រទះតែសេចក្ដីរំខានជាដរាប ជោគអាក្រក់តាំងពីម៉ោង ៦ ដល់ម៉ោង ១៣ និង១២នាទី ជោគល្អតាំងពីម៉ោង ១៣ និង១២នាទី ដល់ម៉ោង ៦ ។

១៥ កើត ព្រះអាទិត្យឱ្យឫក្ស ទេពចរនៅខ្នង ធ្វើការជាមង្គលបុណ្យកុសលបានប្រសើរ ដូចជាបុណ្យខាងផ្នែកពុទ្ធ និយមឬបុណ្យជាតិនិយម ។ ជោគល្អមានតាំងពីម៉ោង ៦ដល់ម៉ោង ១៣និង១២នាទី ជោគអាក្រក់មានតាំងពីម៉ោង១៣ និង១២នាទីដល់ម៉ោង ៦ ។

........................................................

AZCambodia.com ABCCambodia.com AngkorDaily.com AngkorPost.com AngkorLink.com

## ខាងរនោច

១ រោច ព្រះសុក្រឱ្យឫក្ស ព្រះបរមេសូរ ប្រសិទ្ធីពរឫក្ស ធ្វើការសារពើ ចេញជំនួញ លក់ដូរឥវ៉ាន់ សង់គ្រឹះស្ថានថ្មី បានល្អប្រសើរ ។ ជោគល្អតាំងពីម៉ោង ៦ ដល់ម៉ោង ១៨ ជោគអាក្រក់តាំងពីម៉ោង ១៨ នង១នាទី ដល់ម៉ោង ៦ ។

២ រោច ម្រឹត្យឃាត់ហាមឫក្ស ទេពចរនៅហត្ថាទាំងសងខាង ហាមមិនឱ្យធ្វើការសារពើ ចងសម្ព័ន្ធមេត្រីស្ដីដណ្ដឹង គូស្រករ កុំទិញដូរទ្រព្យមានជីវិត កុំគប្បីរៀបពិធីមង្គលការកម្លោះក្រមុំ យកធ្វើជាស្វាមីភរិយាគ្រងរក្សាគ្នាមិនបានយឺនយូរ ពុំនោះរកទ្រព្យបានរក្សាទុកមិនគង់ ។ ជោគអាក្រក់តាំងពីម៉ោង ៦ ដល់ម៉ោង ១៣ និង១២នាទី ជោគល្អតាំងពីម៉ោង ១៣ និង១៣នាទី រហូតដល់ម៉ោង ៦ ។

៣ រោច ព្រះពុធឃាត់ហាមឫក្ស ម្រឹត្យរាំងរាឫក្ស ទេពចរនៅដៃទាំងសងខាង ហាមកុំចងស្ពានមេត្រីស្ដីដណ្ដឹង គូវាសនា កុំគប្បីរៀបអាពាហ៍ពិពាហ៍ យកជាស្វាមីភរិយានៅជាមួយគ្នាមិនបានសេចក្ដីសុខ រកទ្រព្យមិនសូវប្រកប ជោគ រាសីច្រើនធ្លាក់ ។ ជោគអាក្រក់តាំងពីម៉ោង ៦ដល់ម៉ោង១៣ និង១២នាទី ជោគល្អតាំងពីម៉ោង ១៣និង១៣នាទីដល់ ម៉ោង៦ ។

៤ រោច ព្រះព្រហស្បតិ៍ឱ្យឫក្ស ទេពចរនៅធ្មេញ គប្បីធ្វើការមង្គលគ្រប់ប្រការ ចងសម្ព័ន្ធមេត្រីដណ្ដឹងគូគ្រង រៀប អាពាហ៍ពិពាហ៍ផ្សំគូវាសនាជាប្ដី-ប្រពន្ធ នៅរួមរស់ជាមួយគ្នារក្សាទ្រព្យបានល្អ សំបូរញាតិមិត្ត ។ ជោគល្អមានតាំងពីម៉ោង ៦ ដល់ម៉ោង ១៣ និង១២នាទី ជោគល្អអាក្រក់តាំងពីម៉ោង ១៣និង១៣នាទី ដរាបដល់ម៉ោង៦ ។

៥ រោច ព្រះចន្ទឃាត់ហាមឫក្ស ទេពចរនៅចង្កា ស្ដេចយមៈរាំងរាឫក្ស ហាមកុំផ្ដើមធ្វើការចងសម្ព័ន្ធមេត្រីដណ្ដឹង គូគ្រង កុំរៀបអាពាហ៍ពិពាហ៍មុខជាមានហេតុរឿយៗ គ្រប់គ្រងរក្សាគ្នាមិនបានយូរឡើយ ។ ជោគអាក្រក់តាំងពីម៉ោង ៦ ដល់ម៉ោង១៨ ជោគល្អតាំងពីម៉ោង ១៨និង១នាទី ដរាបដល់ម៉ោង ៦ ។

៦ រោច ព្រះអង្គារឱ្យឫក្ស ទេពចរនៅថ្ពាស ធ្វើការមង្គលចងសម្ព័ន្ធស្ដីដណ្ដឹងគូស្រក រៀបពិធីជប់លៀងភ្ញៀវ ធ្វើ ការអ្វីសម្រស់រៀបមង្គលការ បានគ្នាជាប្ដី-ប្រពន្ធមានភោគទ្រព្យសម្បត្តិស្ដុកស្ដម្ភ រុងរឿងចំរើនដល់វង្សត្រកូល ជោគល្អ មានតាំងពីម៉ោង ៦និង១នាទី ដរាបដល់ម៉ោង១៣និង១២នាទី ជោគអាក្រក់មានតាំងពីម៉ោង ១៣និង១២នាទី រហូតដល់ ម៉ោង ៦ ។

៧ រោច ព្រះចៅឃាត់ហាមឫក្ស ទេពចរនៅខ្នង ស្ដេចយមៈជំទាស់ហាមឫក្ស មិនឱ្យធ្វើការចងសម្ព័ន្ធមេត្រីគូ ស្រករ រៀបចំកិច្ចមង្គលការ នៅរក្សាគ្នាមិនស្ថិតស្ថេរចេរកាល ច្រើនកើតរឿងវិវាទប្រកាន់ថ្នាក់គ្នា រកទ្រព្យបានទុកមិនគង់ ច្រើនមានអប្បមង្គលស្ថិតនៅប្រចាំជីវិតរួមរស់ ។ ជោគអាក្រក់មានតាំងពីម៉ោង៦រហូតដល់ម៉ោង ១៨ ជោគល្អមានតាំងពី ម៉ោង១៨និង១នាទី ដរាបដល់ម៉ោង ៦ ។

៨ រោច ព្រះសៅរ៍ហាមឃាត់ឫក្ស ទេពចរនៅមុខហាមមិនឱ្យធ្វើការចងសម្ព័ន្ធមេត្រីស្ដីដណ្ដឹងគូប្រចាំជីវិត មិនឱ្យ រៀបពិធីមង្គលការ នៅរួមជាមួយគ្នាមិនសូវបានសេចក្ដីសុខ ច្រើនប្រទុស្តតបគ្នា អារីះសម្បត្តិ ។ ជោគអាក្រក់មានតាំងពី ម៉ោង ៦ដល់ម៉ោង ១៣និង១២នាទី ជោគល្អមានតាំងពីម៉ោង ១៣និង១៣នាទីរហូតដលម៉ោង ៦ ។

៩ រោច ព្រះសុក្រឱ្យឫក្ស ទេពចរនៅក្បាល ព្រះវិស្ណុកម្មប្រសិទ្ធីឫក្ស ផ្ដើមធ្វើការចងសម្ព័ន្ធមេត្រីស្ដីដណ្ដឹងគូរិយា រៀបអាពាហ៍ពិពាហ៍ បានគ្នាជាសុខ ប្រកបការរបរបានជោគជ័យ ។ ជោគល្អមានតាំងពីម៉ោង ៦ដល់ម៉ោង ១៣និង១២ នាទី ជោគអាក្រក់មានតាំងពីម៉ោង ១៣និង១៣នាទីដល់ម៉ោង ៦ព្រឹក ។

១០ រោច ព្រះកាឡធ្លាក់ទៅពូជវាលស្រែ ព្រះសៅរ៍ឃាត់ហាមឫក្ស ទេពចរនៅសងខាងខ្លួន ហាមមិនឱ្យធ្វើការចងសម្ព័ន្ធមេត្រីស្ដីដណ្ដឹងគូស្រករ រៀបពិធីជាមង្គលផ្សំបុរសនិងនារីជាស្វាមីភរិយា ឱ្យបានគ្នាសំបូរសេចក្ដីក្ដៅក្រហាយច្រើនមានទុក្ខវិបត្តិផ្សេងៗបៀតបៀន ។ ជោគអាក្រក់តាំងពីម៉ោង ៦និង១នាទីរហូតដល់ម៉ោង១៣និង១២នាទី ជោគល្អមានតាំងពីម៉ោង ១៣និង១៣នាទី ដរាបដល់ម៉ោង ៦ព្រឹក ។

១១ រោច ព្រះសុក្រស្ដេចឱ្យឫក្ស ទេពចរនៅលើជើងព្រះឥន្ទ្រ ទ្រង់ប្រសិទ្ធីពរឫក្ស ធ្វើការចងសម្ព័ន្ធមេត្រីស្ដី ដណ្ដឹងគូស្រករ រៀបមមង្គលការផ្សំបុរសនិងស្ត្រីជាប្ដី-ប្រពន្ធបានល្អប្រសើរ ។ ជោគល្អមានតាំងពីម៉ោង ៦និង១នាទីរហូត ដល់ម៉ោង ១៥និង៣៦នាទី ជោគអាក្រក់មានតាំងពីម៉ោង ១៥និង១៧នាទី ដរាបដល់ម៉ោង៦ព្រឹក ។

១២ រោច ម្រឹត្យឃាត់ហាមឫក្ស ទេពចរនៅជើង ហាមមិនឱ្យផ្ដើមកិច្ចការចងសម្ព័ន្ធមេត្រីស្ដីដណ្ដឹងកូនប្រពន្ធ រៀបអាវិហាវិហមង្គលការប្រុស-ស្រី បានគ្នានិងបែកខ្ញែកចេញពីគ្នា កិច្ចការនេះមិនចុះសម្រុងមូលចិត្តគំនិតគ្នា ជោគអាក្រក់មានតាំងពីម៉ោង ៦និង១នាទី ដល់ម៉ោង១៥ និង៣៦នាទី ជោគល្អមានតាំងពីម៉ោង ១៥និង៣៧នាទី រហូតដល់ម៉ោង ៦ព្រឹក ។

១៣ រោច ព្រះចន្ទឱ្យឫក្ស ទេពចរនៅត្រចៀកធ្វើការចងសម្ព័ន្ធស្ដីដណ្ដឹងគូស្រករ រៀបអាពាហ៍ពិពាហ៍បានសុខសួស្ដី នៅរួមរស់រក្សាគ្នាបានយឺនយូរ ប្រកបទៅដោយសេចក្ដីចំរើន បានរុងរឿង ជោគល្អតាំងពីម៉ោង៦និង១នាទី រហូតដល់ម៉ោង១៣និង១២នាទី ជោគអាក្រក់តាំងពីម៉ោង ១៣និង១៣នាទី ដរាបរហូតដល់ម៉ោង ៦ព្រឹក ។

១៤ រោច ព្រះព្រហស្បតិ៍ឱ្យឫក្ស ទេពចរនៅគ្រឹះស្ថាន ព្រះឥន្ទ្រប្រសិទ្ធីពរឫក្ស ធ្វើការសារពើដូចជាចងសម្ព័ន្ធមេត្រីស្ដីដណ្ដឹងគូគ្រង រៀបមង្គលការបានផលប្រសើរ បានគ្នាជាប្ដី-ប្រពន្ធប្រកបទៅដោយសេចក្ដីលូតលាស់ដុះដាល បានបរិបូរណ៍ទៅដោយសេចក្ដីសំបូរសប្បាយជានិច្ចនិរន្ដរ៍ ។ ជោគល្អមានតាំងពីម៉ោង ៦រហូតដល់ម៉ោង១៨ ជោគអាក្រក់មានតាំងពីម៉ោង ១៨និង១នាទីដរាបរហូតដល់ម៉ោង ៦ព្រឹក ។

១៥ រោច ព្រះនារាយណ៍ឱ្យឫក្ស ទេពចរនៅបេះដូង ព្រះចន្ទប្រសិទ្ធីពរឫក្ស ធ្វើការសារពើជាបុណ្យកុសលសព្វបែបយ៉ាងបានប្រសើរ ហាមមិនឱ្យចេញដំណើរទៅកាន់ទីឆ្ងាយដាច់ស្រយាល កុំគប្បីចេញជួញប្រែទៅស្រុកឆ្ងាយ កុំជជែកប្រកែកយកឈ្នះចាញ់ និងមានហេតុឱសស្ថានពុំបានសុខឡើយ ជោគប្រសើរគ្រប់នាទី ។

<u>អធិប្បាយ</u> : ខសង្កេតន័យទេព្ដាឱ្យឫក្ស មានលក្ខណៈស្របគ្នា និងរួមខ្នើយ តាមហេតុពិត បើគន់គូរមើលវេលាមង្គលការតោងយោលដល់ទេព្ដាឱ្យឫក្សផងជាការសំខាន់ ប៉ុន្តែសូមចូលចិត្តឱ្យបានថា "រួមខ្នើយដោយយកជោគល្អនាពេលផ្សំដំណេកនោះ ព្រោះថាតាមប្រពៃណី" ។ ថ្ងៃចូលរោងចាត់ជាថ្ងៃខាងដើម គប្បីរើសយកជោគល្អប្រចាំពេលថ្ងៃ លុះដល់ថ្ងៃសំពះទទួលស្លាពរជ័យ នោះគប្បីជ្រើសយកជោគល្អពេលយប់ ទើបស្របនឹងរយៈរួមខ្នើម ។

ក្នុងឯពាក្យថា "ទេព្ដាឱ្យឫក្ស"និងពាក្យថា "ឃាត់ហាមឫក្ស"ទីនេះគប្បីកំណត់យកថ្ងៃចូលរោងខាងដើម ដែលជាអាទីករណីនៃទីវាមង្គលរបស់លោកអ្នកនាងគួរយកថ្ងៃទេព្ដាឱ្យឫក្សជាកំណត់ ។

បើកាលណាប្រើយោបល់ខ្សែងភ្ជាត់ពីន័យនេះ មុខតែមានការអង្គាសចិត្តដល់មតិលោកអ្នកជាកោសល្យជនជំនាញហោរានិយមមិនខាន ថ្ងៃសម្រេចមង្គលការកំណត់យកថ្ងៃ"ឃាត់ហាមឫក្ស"ជោគល្អស្របនិងរយៈពេលរួមខ្នើម សូមរំឭកដោយស្មោះថា :

អស់លោកអ្នករិះរកជោគវេលារៀបអាពាហ៍ពិពាហ៍ឱ្យបុរស-ស្ត្រីបានឱកាសចាប់ដៃគ្នា សូមប្រើយោបល់ឱ្យបានវែងឆ្ងាយបន្តិច គឺថាលំអិតលៃលកវេលាកុំឱ្យភាន់យោបល់ ដោយប្រកាន់ថារើសយកថ្ងៃសំពះជាពេលនក្ខត្តឫក្ស ពាក្យថា "រៀបមង្គល"គឺសំដៅចំពោះថ្ងៃចូលរោងការ ជោគរួមខ្ទើមសំដៅចំពោះថ្ងៃសំពះទទួលស្លាពរជ័យ ពាក្យ"រៀបមង្គលការ" សំដៅចំពោះថ្ងៃទេព្តាឱ្យឫក្ស សំដៅចំពោះថ្ងៃចូលរោង ឃាត់ហាមឫក្សសំដៅចំពោះថ្ងៃសំពះ ហេតុនេះជោគរួមខ្ទើយហៅ ថា "ឫក្សរាបសារ" ។

..............................................